# អ្នកតានៅតាមខ្លោងទ្វារអង្គរវត្ត

អង្គរវត្ត កសាងឡើងក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី២ (១១១៣-១១៥០) ឧទ្ទិសដល់ទេពក្នុងព្រហ្មញ្ញសាសនា។ តាមរយៈសិលាចារឹកចារនៅក្នុងរវាងសតវត្សរ៍ទី១៦-១៨ គេសម្គាល់ឃើញតែងហៅប្រាសាទនេះថា "ព្រះពិស្ណុលោក" ជាព្រះបរមមរណនាមព្រះបាទសូរ្យវរ្ម័នទី២។[១] ក្នុងគ្រានោះដែរ គេយល់ថាប្រាសាទនេះបានប្តូរជាប្រាសាទពុទ្ធសាសនា ឬខ្លះទុកថាជា"វត្តជេតពន"ផង។[២] ក្នុងសិលាចារឹកសម័យកណ្តាលខ្លះទៀតឱ្យដឹងថា អង្គរវត្តជាទីប្រជុំទេពនិករ និងអារក្ស អ្នកតា បង់បត់ផ្សេងៗ ដែលខ្មែរជឿ និងគោរពតាំងពីបុរាណកាល។[៣] មិនតែប៉ុណ្ណោះ មកដល់សព្វថ្ងៃគេដឹងថាមានអ្នកតាបួនប្រចាំនៅខ្លោងទ្វារអង្គរវត្តគឺ តារាជនៅខ្លោងទ្វារខាងលិច តាពេជ្រនៅខ្លោងទ្វារខាងត្បូង តាគូនៅខ្លោងទ្វារខាងកើត និងតាឡឹកនៅខ្លោងទ្វារខាងជើង (រូបលេខ១)។[៤]




*រូបលេខ១ ទីតាំងអ្នកតាប្រចាំខ្លោងទ្វារអង្គរវត្ត (ប្រភព៖ កែសម្រួលពី **https://the-past.com**)*

---

[១] អាំង ជូលាន និង អាន រស្មី ២០១២: ៤៩

[២] វង់ សុធារ៉ា ២០១២: ៣ និង យ៉ូស៊ីអាគី អ៊ីស៊ីសា្វា៉ា ២០២១: ៥៥-៥៧

[៣] Mahā Bidūr Krassem, 1984: 17-18

[៤] ព្រាប ចាន់ម៉ារ៉ា ២០២០: ៣៥-៣៦

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត

*ជាការពិត ពេលធ្វើដំណើរចូលប្រាសាទអង្គរវត្ត ឆ្លងកាត់តាមខ្លោងទ្វារខាងលិច គេនឹងឃើញបដិមាធំមួយ សាងពីថ្មភក់ តម្កល់នៅបន្ទប់ខាងស្តាំដៃ (រូបលេខ២-៣)។[៥] បដិមានេះមានកម្ពស់ប្រហែល៣ម៉ែត្រ ហើយនៅក្នុងព្រះហស្ត៨ មានកាន់កេតនភណ្ឌផ្សេងៗដែលមើលពុំស្គាល់ជាក់ជាអ្វីឱ្យប្រាកដ។ ចំពោះអ្នកស្រុកហៅបដិមានេះថា"តារាជ" ដែលគេឱ្យន័យថា ជាស្តេចនៃទេពនិករទាំងពួងដែលថែរក្សាអង្គរវត្ត។[៦] ក្នុងជំនឿអ្នកស្រុក បដិមានេះគឺជាអ្នកតាដ៏មានឫទ្ធិបារមី ហើយសូម្បីតែក្នុងអត្ថបទ "និរាសនគរវត្ត" ដែលកវីសុត្តន្តប្រីជា ឥន្ទ លើកជាកាព្យតាំងពីដើមសតវត្សរ៍ទី២០ ក៏បញ្ជាក់ថាអ្នកស្រុកហៅបដិមានេះថា "អ្នកតាមហារាជ"។[៧] ប៉ុន្តែយ៉ាងណាក្តី តាមយោបល់ខ្លះយល់ថា តារាជ គឺជាបដិមាព្រះនារាយណ៍។*



*រូបលេខ២ បដិមាតារាជមើលពីចំហៀងឆ្វេង* **(រូបថតឆ្នាំ២០១៤)**



*រូបលេខ៣ បដិមាតារាជមើលពីចំហៀងស្តាំ* ***(ប្រភព៖ EFEO, 1949)***

---

[៥] *ជួនកាលគេហៅទីនោះថា "គុកតារាជ"។*

[៦] *រស់ សុខុម ២០០៥-២០០៦: ៥៩*

[៧] *សុត្តន្តប្រីជា ឥន្ទ ១៩៦៩: ៦៦-៦៧*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

តាពជ គឺជាអ្នកតាដ៏ល្បីល្បាញដែលអ្នកផងជិតឆ្ងាយតែងចូលគោរពបូជាស្ទើរមិនហ៊ានរំលងឡើយ។ ប្រសិនបើសង្កេតឱ្យជិតដល់ គេឃើញមានសំណែនផ្សេងៗថ្វាយតាពជពោរពាសពុំលុះពេល ពោលគឺរាប់ទាំងគ្រឿងស្លៀកដណ្តប់ ស្វាធម៌ បាយស្រី បង្អែមចម្អាបនានា តាមសេចក្តីជ្រះថ្លារបស់អ្នកមានជំនឿ (រូបលេខ២៤-៦)។ វត្ថុទាំងអស់នោះស្តែងឱ្យឃើញថា តាពជពុំមែនគ្រាន់តែជាអ្នកតាសំខាន់សម្រាប់តែអ្នកស្រុកអាយទេ តែក៏សំខាន់ក្នុងជំនឿរបស់អ្នកចម្ងាយដែរ។ លើសពីនេះ នៅរៀងរាល់ថ្ងៃ៣ កើត ខែមាឃ អ្នកស្រុកតែងធ្វើពិធីតាមទំនៀមនៅមុខប្រាសាទអង្គរវត្ត ដែលហៅថា "ឡើងមាឃ" ហើយមានទាំងកិច្ចបញ្ចូលបញ្ជាន់រូបអ្នកតាផ្សេងៗរួមទាំងតាពជផង។[៨]





រូបលេខ២៤-៥ តង្វាយ និងគ្រឿងសក្ការៈផ្សេងៗថ្វាយដល់តាពជ

រូបលេខ២៦ បញ្ចូលរូបឡើងមាឃ (រូបថត៖ រស់ សុខុម, យសោធរ)

KHMER CIVILIZATION

ដោយឡែកចំពោះតាពេជ្រស្ថិតនៅខ្លោងទ្វារខាងត្បូង ឬហៅថា "គុកតាពេជ្រ" (រូបលេខ២៧) គឺជាអ្នកតាដែលសូវល្បីល្បាញដូចតាពជទេ តែតាំងពីដើមរហូតមកដល់សព្វថ្ងៃអ្នកតានេះក៏ហាក់មិនកំបាំងភ្នែកអ្នកមានជំនឿដែរ។ បើយោងតាមអ្នកស្រាវជ្រាវយល់ថា តាពេជ្រគឺជាបដិមាព្រះពុទ្ធប្រក់នាគ (រូបលេខ២៨-៩)។[៩] ចំណែកអ្នកស្រុកយល់ថារូបតា ពេជ្រកើត

[៨] សូមអាន "ឡើងមាឃ" តាមទំនៀមអ្នកស្រុកអង្គរ ដោយ ហៀន សុវណ្ណមរកត ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/26231 ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣

[៩] អាំង ជូលាន, ២០០០

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ពីដីដំបូកសុទ្ធសាធ ពោលគឺពុំមានព្រះពុទ្ធបដិមានៅខាងក្នុងទេ។ តាមជំនឿអ្នកស្រុកខ្លះជឿថា តាពេជ្រជាគឺជាអ្នកតាដែលកបនឹងការបន់ស្រន់ព្យាបាលជំងឺ ឬហៅថា "គ្រូថ្នាំ" ហើយខ្លះទៀតយល់ថា តាពេជ្រជាមេទ័ពដ៏ខ្លាំងពូកែជាដើម។



រូបលេខ៧ ខ្លោងទ្វារខាងត្បូង ឬគុកតាពេជ្រ

បច្ចុប្បន្ន ឫទ្ធានុភាពរបស់តាពេជ្រហាក់មិនថមថយឡើយ។ នៅចំពោះមុខតាពេជ្រ គេឃើញតង្វាយគ្រឿងសក្ការៈយ៉ាងភ្លឺផ្លេកស្អេកស្កះ។ មិនតែប៉ុណ្ណោះនៅគុកតាពេជ្រ អ្នកផងពុំហ៊ានសូម្បីពាក់ស្បែកជើង ឬពាក់មួកដើរឆ្លងកាត់ចេញចូលទេ។ បើរម្លឹកកាលពីសម័យមុនផង គេដឹងថាតាពេជ្រមានបារមី និងមានចរិកកាចខ្លាំងណាស់ សូម្បីតែសត្វស្លាបដែលហើរកាត់ក៏ត្រូវធ្លាក់ងាប់ដែរ។ លើសពីនេះ គេតែងហាមស្ត្រីមានផ្ទៃពោះមិនឱ្យដើរទៅក្បែរនោះសោះឡើយ។ គេនិទានថានៅសម័យបារាំង ក្នុងអាណត្តិរបស់លោក ហង់រី ម៉ាកហ្សាល់ *(Henri Marchal)* ធ្វើជាប្រធានអភិរក្សដ្ឋានអង្គរ (១៩១៦-១៩២០, ១៩២២-១៩៣៦ និង១៩៤៨-១៩៥៣) គេហាមកម្មករមិនឱ្យទៅក្បែរខ្លោងទ្វារតាពេជ្រ។ កាលនោះគេថែមទាំងជឿថា មរណភាពរបស់លោក ហ្ស៊កក ទ្រូវេ *(Georges Trouvé, 1902-1935)* ដែលជាអ្នកស្រាវជ្រាវជាតិបារាំង មកស្លាប់នៅស្រុកខ្មែរទាំងក្មេងវ័យ គឺមកពីហេតុធ្វើឱ្យប៉ះពាល់ដោយប្រការណាមួយលើតាពេជ្រ។[១០]

---

[១០] Keiko Miura 2004: 76-77

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៨ តាពេជ្រកាលពីរវាងជាង២០ឆ្នាំមុន (រូបថត៖ អាំង ជូលាន, ឆ្នាំ២០០០)



រូបលេខ៩ រូបសំណាកតាពេជ្រនិងតង្វាយ

ចំណែកឯតាឡឹកស្ថិតនៅខ្លោងទ្វារខាងជើង (រូបលេខ១០) គឺជាអ្នកតាដែលគេដឹងថាពុំមានរូបសំណាកអ្វីជាសម្គាល់ឡើយ។ ប៉ុន្តែនៅខ្លោងទ្វារនេះ គេឃើញមានអាសនៈ និងគ្រឿងសក្ការៈតម្កល់នៅក្នុងបន្ទប់ទាំងសងខាង។ នៅក្នុងបន្ទប់ខាងកើត គឺមានតង្វាយបាយសីប្រាំថ្នាក់១គូ បាយសី៣ថ្នាក់១គូ និងបាយសីប៉ាក់ចាម១គូ ដែលធ្វើពីក្រដាសពណ៌មាសយ៉ាងភ្លឺផ្លេក (រូបលេខ១១)។ ចំពោះនៅក្នុងបន្ទប់ខាងលិចវិញ គេឃើញមានអាសនៈខ្ពស់មួយធ្វើអំពីឈើ ហើយចែកជាថ្នាក់ៗ។ នៅថ្នាក់លើបំផុត គេតម្កល់បាយសី៧ថ្នាក់ រៀងចុះរហូតមកដល់បាយសីប៉ាក់ចាម១គូៗ ដែលមូរពីក្រដាសពណ៌បៃតង។ មិនតែប៉ុណ្ណោះ នៅលើអាសនៈនេះគេឃើញមានស្លាធម៌ បាយសី ផ្កាឈូក និងតង្វាយថ្មីៗផ្សេងៗទៀតដែរ (រូបលេខ១២-១៣)។ គ្រឿងសក្ការៈ និងតង្វាយទាំងអស់នេះគេសម្គាល់ឃើញមានគេយកមកថ្វាយជារឿយៗពុំសូវដាច់រយៈដែរ ជាពិសេសគឺនៅក្នុងថ្ងៃសីល ឬថ្ងៃពេញបូរមីជាដើម។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១០ ខ្លោងទ្វារតាឡឹក (ខាងជើង)



រូបលេខ១១ គ្រឿងសក្ការៈក្នុងបន្ទប់ខាងកើត





រូបលេខ១២-១៣ គ្រឿងសក្ការៈ និងតង្វាយផ្សេងៗថ្វាយកក្នុងបន្ទប់ខាងលិច

រីឯអ្នកតាគូ ឬតាគូ ដែលស្ថិតនៅខ្លោងទ្វារខាងកើតវិញ ក៏ជាអ្នកតាដែលពុំមានរូបសំណាកជាសម្គាល់ដូចតាឡឹកនៅខ្លោងទ្វារខាងជើងដែរ។ ប៉ុន្តែនៅត្រង់កណ្តាលបន្ទប់នៃខ្លោងទ្វារតាគូ ឬគុកតាគូនេះ គេឃើញមានគំនរបំណែកថ្មប្រាសាទតម្រៀបលើកំណល់ស៊ីម៉ងត៍រាងបួនជ្រុង និមិត្តឱ្យតាគូ(?)។ បំណែកថ្មប្រាសាទទាំងនោះ គេរុំក្រណាត់មួយផ្ទាំងលំនាំដូចតង្វាយសម្លៀកបំពាក់ ឬគ្រឿងដណ្តាប់ផ្សេងៗដល់បដិមាដែរ។ នៅខាងមុខនោះគេក្រាលក្រណាត់សមួយផ្ទាំង និងមានកន្លែងសម្រាប់អុជធូបមួយ។ អ្វីដែលគួរឱ្យកត់សម្គាល់ គេឃើញកន្ទុយបារីយ៉ាងស្អេកស្កះក្នុងកន្លែងអុជធូបនោះ (រូបលេខ១៤-១៥)។ ទិដ្ឋភាពនេះទំនងឱ្យគេកាត់យល់បានថា តង្វាយពិសេសសម្រាប់តាគូគឺបារី។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១៨ ខ្លោងទ្វារតាគូ (ទិសខាងកើត)



រូបលេខ១៩ គំនរបំណែកថ្មនៅខ្លោងទ្វារតាគូ

សរុបសេចក្តីមក នៅតាមខ្លោងទ្វារទាំងបួនទិសនៃប្រាសាទអង្គរវត្តសុទ្ធសឹងតែមានអមនុស្សចាំថែរក្សា។ ប៉ុន្តែក្នុងចំណោមនោះ តាពជជាអ្នកតាមានឫទ្ធិបារមី និងល្បីល្បាញទាំងក្នុងក្រសែភ្នែកអ្នកស្រុក និងភ្ញៀវទេសចរ។ រីឯតាពេជ្រ ជាអ្នកតាដែលអ្នកស្រុកគោរព និងស្គាល់ច្បាស់ដូចតាពជដែរ។ ចំពោះតាឡឹក និងតាគូ ជាអ្នកតាដែលពុំមានរូបតំណាង ហើយទំនងជាស្គាល់ច្បាស់តែក្នុងភ្នែកអ្នកស្រុក ដ្បិតរាល់ពេលគេធ្វើពិធីឡើងមាយម្តងៗ គេតែងអំពាវនាវហៅអ្នកតាទាំងបួនទិសនោះ។ ប៉ុន្តែយ៉ាងណាក្តី មុខងារដាក់លាក់របស់អ្នកតាទាំងនោះក្នុងជំនឿរបស់អ្នកស្រុក គួរតែជាប្រធានបទសិក្សាវែងឆ្ងាយទៅមុខ៕

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង


ព្រាប ចាន់ម៉ារ៉ា

២០២០, "ជំនឿផ្សេងៗ និងពុទ្ធសាសនានៅកម្ពុជា", ព្រឹត្តបត្រសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, លេខ៣, ទំ.៣១-៤៥, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ

យ៉ូស៊ីអាគី អ៊ីស៊ីស្សាវ៉ា

២០២១, "ប្លង់អង្គរវត្តរបស់ជប៉ុនដែលចាស់ជាងគេលើលោក៖ ប្លង់គូរនៅស.វ.ទី១៧ដែលគេអះអាងថាជាប្លង់វត្តជេតពន",កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ, លេខ១៦, ទំ.៥៥-៧៣, យសោធរ, ភ្នំពេញ

រស់ សុខុម

២០០៥-២០០៦,"តារាជនៅប្រាសាទអង្គរវត្ត", កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ, លេខ១, ទំ.៥៩-៦១, Friends of Khmer Culture, ភ្នំពេញ

វង់ សុធារ៉ា

២០១២, សិលាចារឹកនៃប្រទេសកម្ពុជាសម័យកណ្ដាល, នគរវត្ត, ភ្នំពេញ

សុត្តន្តប្រីជា ឥន្ទ

១៩៦៩, និរាសនគរវត្ត, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

អាំង ជូលាន និង អាន រស្មី

២០១២, "ព្រះពិស្ណុលោក", កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ, លេខ៨, ទំ. ៤៩-៥៣, យសោធរ, ភ្នំពេញ

អាំង ជូលាន

២០០០, មនុស្ស និងដី, រៃយំ, ភ្នំពេញ

Keiko Miura

2004, *Contested Heritage People of Angkor,* SOAS, London

Mahā Bidūr Krassem

1984, *Inscriptions Modernes d'Angkor,* [Nouvelle preface de Saveros Pou], Cedoreck, Paris


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត